**“គេចាត់ទុកយើងដូចសត្វ”**

ការប្រព្រឹត្តមិនត្រឹមត្រូវលើអ្នកអាស្រ័យលើគ្រឿងញៀនព្រមទាំង“មនុស្សគេមិនចង់បាន”

ក្នុងមណ្ឌលឃុំឃាំងគ្រឿងញៀននៅកម្ពុជា

## សេចក្តីសង្ខេប

ស្មោញ ជាបុរសមានរាងស្តើង សម្តីស្រទន់ ក្នុងវ័យប្រមាណ ២៥ឆ្នាំ ។ នៅពេលអង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch) បាននិយាយជាមួយគាត់ក្នុងពេលរាត្រីមួយ នាពាក់កណ្តាលឆ្នាំ ២០១៣ គាត់អង្គុយយ៉ាងស្ងៀមស្ងាត់ នៅក្នុងសួនច្បារសាធារណៈមួយក្នុងរាជធានីភ្នំពេញនៃប្រទេសកម្ពុជា ។ គាត់បានរៀបរាប់ប្រាប់ថា គាត់រកស៊ីចិញ្ចឹមជីវិតដោយដើររើសអេតចាយនៅតាមផ្លូវនានា និងយកទៅលក់អោយឈ្មួញកណ្តាលសម្រាប់យកទៅច្នៃធ្វើវត្ថុប្រើប្រាស់ឡើងវិញ ។

ថ្មីៗនេះការរស់របស់គាត់បានប្រែប្រួលទៅជាលំបាកជាងមុនយ៉ាងខ្លាំង ។ នៅដើមខែវិច្ឆិកា ឆ្នាំ ២០១២ ឆ្មាំសួនច្បារបានប្រមូលគាត់ នៅពេលប្រហែលពីរអាទិត្យមុនប្រធានាធិបតីសហរដ្ឋអាមេរិក បារ៉ាក់ អូបាម៉ា បានមកដល់ភ្នំពេញ ដើម្បីចូលរួមក្នុងកិច្ចប្រជុំកំពូលរបស់សមាគមប្រជាជាតិអាស៊ីអគ្នេយ៍ (អាស៊ាន) ដែលបានផ្តើមនៅថ្ងៃទី១៩ ខែវិច្ឆិកា ។ គេមិនបាននិយាយប្រាប់ ស្មោញ អំពីមូលហេតុឃុំខ្លួនទេ ។ នៅរាត្រីនោះ គេបានចាប់គាត់ដាក់ក្នុងឡានធំមួយ ដែលមានផ្ទុកអ្នកផ្សេងរាប់សិបនាក់ ដូចជាអ្នករកស៊ីផ្លូវភេទ អ្នកសុំទាន និងក្មេងអនាថាតាមចិញ្ចើមថ្នល់ ។

គេបានដឹកពួកគាត់តាមរថយន្តទៅកាន់អាគាររបស់រដ្ឋាភិបាលមួយនៅជាយក្រុង ឈ្មោះ ឱកាសខ្ញុំ ដែលមិនមែនជាគុក ឬពន្ធនាគារទេ ប៉ុន្តែដែលគេអះអាងថាជាកន្លែងសម្រាប់ព្យាបាល និងស្តារនីតិសម្បទាអ្នកអាស្រ័យលើគ្រឿងញៀន ។ ដូចគ្នានឹងអ្នកផ្សេងទៀតនៅក្នុងរថយន្តដែរ ស្មោញ មិនត្រូវការការព្យាបាលការអាស្រ័យលើគ្រឿងញៀនទេ ។ ពីមុនមក គាត់ធ្លាប់បានជក់គ្រឿងញៀនប្រភេទ "យ៉ាម៉ា" ឬមេតំហ្វេតាមីន ដែរ ពេលគាត់មានវ័យជំទង់ ប៉ុន្តែគាត់មានមោទនភាពដោយបានឈប់ប្រើបគ្រឿងញៀនបួនឆ្នាំមកហើយ ដោយសារការតាំងចិត្តដោយខ្លួនឯង ។

គាត់បានរៀបរាប់ប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្សថា បុគ្គលិកមណ្ឌលបានវាយនិងធ្វើបាបរូបគាត់ ព្រមទាំងអ្នកជាប់ឃុំឃាំងឯទៀត ។ ប៉ុន្មានអាទិត្យក្រោយមក គាត់និងអ្នកជាប់ឃុំឃាំងមួយចំនួន បានប្តេជ្ញាចិត្តលួចរត់៖ "ខ្ញុំទ្រាំនឹងការវាយនឹងរំពាត់មិនបានទេ" គាត់បាននិយាយពន្យល់ ។ នាយប់មួយ ពួកគេ

បានហែកទ្វារចេញពីបន្ទប់ដេក  ហើយអ្នកខ្លះបានផ្លោះរបងខាងក្រៅរត់ចេញរួច ។ ប៉ុន្តែ ស្មោញ មិនអាចលោតចេញពីខ្សែលួសបន្លានៅខាងលើរបងបាន ក៏ត្រូវឆ្មាំឆក់នឹងដំបងអគ្គីសនី បណ្តាលអោយគាត់ធ្លាក់មកដីវិញ ។ បន្ទាប់មក ពួកអ្នកយាមបានវាយដំគាត់យ៉ាងសាហាវរហូតសន្លប់ ។ ស្អែកឡើង គេបានបន្តធ្វើទណ្ឌកម្មមកលើរូបគាត់ទៀត ។

> គេវាយខ្ញុំនិងរំពាត់ដូចវាយសេះអញ្ចឹង ។ វាយតែមួយរំពាត់ក៏រលាត់ស្បែកហើយ ។ អ្នកយាមម្នាក់បាននិយាយថា៖ "អញវៃវ្អែងដើម្បីអោយចេះរៀនគោរពវិន័យក្នុងមណ្ឌល"... ខ្ញុំបានអង្វរគេកុំអោយវាយ ។ ពេលនោះខ្ញុំបានគិតថាខ្លួនខ្ញុំលែងជាមនុស្សទៀតហើយ ។

ស្មោញ ជាប់ឃុំអស់រយៈពេលប្រហែលបីខែ ។ ទោះបីគាត់បានឈប់ប្រើប្រាស់គ្រឿងញៀនអស់ពេលយូរមកហើយ មុនជាប់ឃុំនៅមណ្ឌលឱកាសខ្ញុំ គាត់បានចាប់ផ្តើមប្រើប្រាស់គ្រឿងញៀនឡើងវិញក្រោយពេលដោះលែងមិនយូរប៉ុន្មាន ៖

> ខ្ញុំជិតឆ្កួតដោយសារគេវាយខ្ញុំពេលនៅក្នុងមណ្ឌល ។ ឥឡូវខ្ញុំហិតការអស់មួយកំប៉ុងក្នុងមួយថ្ងៃ ។ បើខ្ញុំមានលុយ ខ្ញុំជក់ ម៉ា ។ ខ្ញុំខឹងណាស់ ពីព្រោះពួកគេបានចាត់ទុកយើងដូចសត្វអញ្ចឹង ។

បច្ចុប្បន្ននេះ មណ្ឌលឃុំឃាំងគ្រឿងញៀនមានចំនួនប្រាំបី ពង្រាយទូទាំងប្រទេសកម្ពុជា ដែលជារួមឃុំមនុស្សប្រហែល ១០០០ នាក់ ទាំងបុរស ស្ត្រី និងកុមារ ក្នុងពេលតែមួយ ជាមធ្យម ។ ភាគច្រើនត្រូវបានឃុំឃាំងពីបីទៅប្រាំមួយខែ ទោះបីការឃុំឃាំងខ្លះមានរយៈពេល រហូតដល់ ១៨ ខែក៏ដោយ ។ យោង

តាមស្ថិតិរបស់រដ្ឋាភិបាល មនុស្សចំនួនប្រមាណ ២២០០នាក់ត្រូវបានជាប់ឃុំនៅក្នុងមណ្ឌលទាំងនោះពេញមួយឆ្នាំ ២០១២។ អ្នកជាប់ឃុំភាគច្រើនជាបុរសក្មេង អាយុពី ១៨ ឆ្នាំ ទៅ ២៥ ឆ្នាំ ប៉ុន្តែ ក្នុងចំណោមចំនួនសរុប មានកុមារយ៉ាងហោចណាស់ ១០% ។

នៅក្នុងមណ្ឌលទាំងនេះ ទារុណកម្ម និងប្រព្រឹត្តកម្មយង់ឃ្នង ជារឿងធម្មតា ហើយត្រូវបានប្រើជាការផ្តន្ទាទោសផង និងជាផ្នែកជាប្រចាំនៃ "កម្មវិធី" ផងដែរ ។ បុគ្គលិកបានតែងតាំងអ្នកជាប់ឃុំខ្លះធ្វើជាឆ្មាំក្រៅផ្លូវការ ដែលវាយដំអ្នកទើបចូលថ្មីជាញឹកញាប់ ។ ការវាយដំលើរូបរាងកាយដ៏ឃោរឃៅដោយបុគ្គលិក ទំនងជាបានកើតឡើងជាញយៗ ។ ឈ្មោះ បូន ដែលមានអាយុប្រហែល ២០ ឆ្នាំផ្លាយ បានឈរខុសជួរនៅពេលដើរក្បួនហាត់របៀបយោធា ហើយត្រូវបានអោយលូនលើដី និងរងការវាយដំនឹងទុយោទឹកកោះស៊ូជាច្រើនដងដោយឆ្មាំ ។ សុក្រម ជាស្ត្រីអាយុប្រមាណ ៤៥ ឆ្នាំ ត្រូវបានឆ្មាំវាយនឹងដំបងដោយសារតែសុំទៅបង្គន់បត់ជើង ។ គាត់និយាយថាមុខមាត់របស់គាត់ហើមអស់រយៈពេលជាច្រើនអាទិត្យក្រោយមក ។ អស្សុជ អាយុប្រមាណ ៣០ ឆ្នាំផ្លាយ បានឃើញនាយកមណ្ឌលមួយយកផាងដូងវាយអ្នកជាប់ឃុំជាមួយម្នាក់ទៀតយ៉ាងខ្លាំងរហូតដល់បាក់ផាងដូង ។

អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានធ្វើការស្រាវជ្រាវអំពីមណ្ឌលឃុំឃាំងគ្រឿងញៀននៅកម្ពុជា តាំងពីឆ្នាំ ២០០៩ ។ រដ្ឋាភិបាលកម្ពុជា បានបង្ហាញការមិនអើពើដោយគ្មានមេត្តា ចំពោះសុខមាលភាពមនុស្សរាប់ពាន់នាក់ ដែលភាគច្រើនជាអ្នកត្រូវផាត់ចេញពីសង្គម រួមមានកុមារជាច្រើនផង ដែលរដ្ឋាភិបាលបានបញ្ជូនទៅកាន់មណ្ឌលទាំងនោះ អោយទទួលរងការបំពានយ៉ាងសាហាវ តាមគេនឹកឃើញ ។ កំហុសកំប៉ិកកំប៉ុកដូចជាការដើរខុសជំហាននៅក្នុងលំហាត់របៀបទាហាន ឬក៏សូត្រខុសពាក្យពេលច្រៀងនៅពេលហាត់ក្បួន អាចបណ្តាលឲ្យអ្នកជាប់ឃុំទទួលរងទណ្ឌកម្មដ៏ព្រៃផ្សៃ ។

គ្មានអ្វីគួរឲ្យភាន់ច្រឡំទេថា មណ្ឌលទាំងនេះគ្មានបំណងជួយអ្នកអាស្រ័យលើគ្រឿងញៀនឡើយ ។

ផ្ទុយទៅវិញ អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានរកឃើញថាមណ្ឌលទាំងនេះ គឺជាមធ្យោបាយសម្រាប់ដាក់ឃុំពួកអ្នកប្រើគ្រឿងញៀន និងអ្នកដែលសង្ស័យថាប្រើគ្រឿងញៀន ដោយចាក់សោចោល និងដោយសារកិច្ចប្រឹងប្រែង និងថ្លៃចំណាយមានទំហំតិចជាងការនាំខ្លួនពួកគេទៅកាត់ទោសក្នុងប្រព័ន្ធយុត្តិធម៌ និងដាក់ក្នុងពន្ធនាគារ ។ ទោះបីច្បាប់ប្រឆាំងគ្រឿងញៀនបច្ចុប្បន្ននៅកម្ពុជា មានការធានា

ដោយនីតិវិធីធំទូលាយមួយចំនួនតូច ដើម្បីការពារកុំឲ្យមនុស្សត្រូវគេបង្ខិតបង្ខំឲ្យចូលក្នុងមណ្ឌលឃុំឃាំងគ្រឿងញៀនក៏ដោយ ក៏ការធានាទាំងនេះមិនរឹងមាំទេ ហើយគ្មានអ្នកណាអើពើដឹងឮឡើយ ។

ការខ្វះការការពារដោយកិច្ចដំណើរការត្រឹមត្រូវតាមផ្លូវច្បាប់ មានន័យថាមណ្ឌលទាំងនេះក៏ជាកន្លែងដ៏ងាយស្រួលសម្រាប់ឃុំឃាំងមនុស្សដែលអាជ្ញាធរកម្ពុជាចាត់ទុកពួកគេជា "មនុស្សគេមិនចង់បាន" ដូចជាអ្នកគ្មានផ្ទះសម្បែង អ្នកសុំទាន ក្មេងអនាថាតាមចិញ្ចើមថ្នល់ អ្នករកស៊ីផ្លូវភេទ និងមនុស្សដែលមានឬត្រូវគេឃើញថាមានសមត្ថភាពខុសគេខាងផ្លូវចិត្ត ឬខាងការវិវត្តន៍ ។ មនុស្សប្រភេទនេះត្រូវបានឃុំឃាំងក្នុងការបង្ក្រាបម្តងម្កាល ដែលកើតឡើងជាញឹកញយមុនពេលមានកិច្ចប្រជុំធំៗលេចមុខមាត់ ឬក្នុងពេលទស្សនកិច្ចរបស់អ្នកមុខអ្នកការបរទេស ។

ក៏ប៉ុន្តែ មណ្ឌលទាំងនោះមិនគ្រាន់តែជាទីកន្លែងងាយស្រួលសម្រាប់អាជ្ញាធរបញ្ជូលក្នុងក្រោល នូវជនដែលគេចាត់ទុកថាគួរត្រូវបដិសេធប៉ុណ្ណោះទេ មណ្ឌលទាំងនេះហាក់បីដូចជាមានបំណងដើម្បីប្រើប្រាសសម្រាប់ផ្តន្ទាទោសមនុស្សដែលគេចាត់ទុកថាមានការខ្វះខាតខាងសីលធម៌ ដោយសារការប្រើលើគ្រឿងញៀន ឬដោយសារជាអ្នកគ្មានផ្ទះសម្បែង ឬអ្នកសុំទាន ឬអ្នករកស៊ីផ្លូវភេទ ។

បួនឆ្នាំមុន អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានបោះពុម្ពផ្សាយរបាយការណ៍មួយក្រោមចំណងជើងថា *"ស្បែកដាច់ជាប់ខ្សែភ្លើង" ៖ ការចាប់ខ្លួនខុសច្បាប់ ការឃុំឃាំងដោយគ្មានឈរលើច្បាប់ និងទារុណកម្មអ្នកប្រើប្រាស់គ្រឿងញៀននៅកម្ពុជា* ។ ឈរលើបទសម្ភាសន៍ជាមួយមនុស្សដែលធ្លាប់ជាប់នៅក្នុងមណ្ឌលឃុំឃាំងគ្រឿងញៀន ពីឆ្នាំ ២០០៦ ដល់ ២០០៨ របាយការណ៍បានលំអិតអំពីការរំលោភបំពានផ្សេងៗ រួមមានការវាយនិងរំពាត់ ការវាយដំ ទណ្ឌកម្មឃោរឃៅ ហិង្សាផ្លូវភេទ និងការធ្វើពលកម្មដោយបង្ខំ ។

របាយការណ៍លើកនេះ គឺផ្អែកលើបទសម្ភាសន៍ជាមួយមនុស្ស ៣៣ នាក់ ដែលធ្លាប់បានជាប់ឃុំនៅក្នុងមណ្ឌលតាំងពីពេលនោះមក (ចន្លោះពាក់កណ្តាលឆ្នាំ ២០១១ និងពាក់កណ្តាលឆ្នាំ ២០១៣) ។ ការឃុំឃាំងដោយមិនឈរលើច្បាប់ និងដោយគ្មានកិច្ចដំណើរការត្រឹមត្រូវតាមច្បាប់នៅតែបន្ត ដូចគ្នានឹងរបាយការណ៍លើកមុនដែរ គ្មានអ្នកណាម្នាក់ដែលអង្គការឃ្លាំមើលសិទ្ធិមនុស្សបានសម្ភាសន៍ បានជួបមេធាវី ឬចៅក្រម ឬត្រូវបានបញ្ជូនទៅកាន់តុលាការក្រោយពេលចាប់ខ្លួន ឬក្នុងពេលដែលពួកគេកំពុង

ជាប់ឃុំនៅក្នុងមណ្ឌលឡើយ ។ ទារុណកម្មនៅក្នុងមណ្ឌលទាំងនេះ នៅតែបន្តកើតមានផងដែរ ។ អតីតអ្នកជាប់ឃុំឃាំងទាំងឡាយ បានប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្សថា ពួកគេបានរងការវាយដំ ការវាយយ៉ាងខ្លាំងនឹងទុយយោទឹកកៅស៊ូ ទណ្ឌកម្មដោយបង្ខំអោយលូនលើដីក្រួស ឬឈរនៅក្នុងរណ្តៅទឹកស្អុយ ការរំលោភផ្លូវភេទ និងការបង្ខំឲ្យអោយធ្វើពលកម្ម ។

មណ្ឌលឃុំឃាំងគ្រឿងញៀននៅកម្ពុជា មានសភាពខុសគ្នាពីកន្លែងមួយទៅកន្លែងមួយ។ នៅផ្នែកខ្លះនៃប្រទេស មណ្ឌល (ដូចជា មណ្ឌលឱកាសខ្ញុំ ដែលស្ថិតនៅភ្នំពេញ) មានរបងខ្ពស់ សណ្ឋានដូចពន្ធនាគារស្ថិតនៅជាយក្រុង ។ ចំណែកកន្លែងឯទៀត មណ្ឌលអាចស្ថិតនៅក្នុងបរិវេណបញ្ជាការដ្ឋាននគរបាល ឬកងរាជអាវុធហត្ថ ។ មានមណ្ឌលមួយ កំពុងតែស្ថិតក្រោមការគ្រប់គ្រងនៃទីបញ្ជាការដ្ឋានយោធាខេត្ត ។

មិនថាមណ្ឌលប្រភេទណាទេ អ្នកជាប់ឃុំត្រូវបានចាក់សោនៅពេលយប់ឲ្យនៅក្នុងបន្ទប់ដែលមានសណ្ឋានដូចបន្ទាយទាហាន ហើយនៅពេលព្រឹក ពួកគេត្រូវបានបង្ខំឲ្យហាត់ប្រាណបែបទាហានដ៏នឿយហត់ នៅលើទីធ្លាចតរថយន្ត ឬទីធ្លាសម្រាប់ដើរក្បួនយោធាក្នុងបរិវេណមណ្ឌល ។ នៅមណ្ឌលខ្លះទៀត ពេលទំនេរដែលនៅសល់ពេលថ្ងៃ គឺជាការចំណាយពេលដ៏ឥតប្រយោជន៍ ដោយឡែកអ្នកជាប់ឃុំខ្លះទទួលបញ្ជាអោយធ្វើការងារនៅក្នុងសួនបន្លែ ឬចង្ក្រានបាយនៃមណ្ឌល ។ អ្នកដែលបដិសេធមិនព្រមធ្វើការអាចនឹងទទួលរងការវាយដំ ។

អង្គការឃ្លាំមើលសិទ្ធិមនុស្សបានដឹងថា មណ្ឌលមួយចំនួនបានបង្ខំអោយអ្នកជាប់ឃុំសាងសង់អគារថ្មីនៅលើទីធ្លាក្នុងមណ្ឌល ឬបញ្ជូនជាកងពលកម្មអោយទៅសង់ផ្ទះ ហើយចំណែកនៅមណ្ឌលមួយផ្សេងទៀតគេអោយជួយសង់សណ្ឋាគារថ្មីមួយ ។ អតីតអ្នកជាប់ឃុំឃាំងមួយចំនួននៅភ្នំពេញ បាននិយាយថាពួកគេបានជាប់ពាក់ព័ន្ធក្នុងការធ្វើសំណង់នៅផ្ទះរបស់នាយកមណ្ឌលក្នុងពេលនោះ ។

ចាប់តាំងពីឆ្នាំ ២០១០ មក ចំនួនមណ្ឌលនៅប្រទេសកម្ពុជាបានថយចុះពី ១១ កន្លែងក្នុងឆ្នាំ ២០១០ មកត្រឹម ៨ កន្លែងក្នុងឆ្នាំ ២០១៣ ។ ទោះបីហេតុផលបិទទ្វារមិនត្រូវបានប្រកាសជាសាធារណៈក្តី  កម្ពុជាបានបិទទ្វារមណ្ឌលមួយ គឺ "មណ្ឌលស្តារយុវនីតិសម្បទាចោមចៅ" ស្ថិតនៅភ្នំពេញ ក្រោយការផ្សព្វផ្សាយភ្លាមៗ នូវរបាយការណ៍ "*ស្បែកដាច់ជាប់ខ្សែភ្លើង*" ហើយបានបិទមណ្ឌលតូចៗ ពីរថែមទៀត ។

ទោះបីយ៉ាងណាក៏ដោយ ចំនួនមនុស្សសរុបដែលជាប់នៅក្នុងមណ្ឌលទាំងអស់នោះនៅថេរដដែល ហើយការបិទមណ្ឌលបីកន្លែងខាងលើ ត្រូវបានជំនួសដោយបើកអគារថ្មីមួយសម្រាប់ដាក់ស្ត្រីនៅមណ្ឌលឧិកាសខ្ញុំ ។ កាន់តែគួរឲ្យព្រួយបារម្ភជាងនេះទៅទៀត គឺការដែលរដ្ឋាភិបាលបានប្រកាសផែនការសង់មណ្ឌល "ជាតិ"ព្យាបាលគ្រឿងញៀនមួយនៅខេត្តព្រះសីហនុ ក៏ប៉ុន្តែ រហូតដល់ពាក់កណ្តាលឆ្នាំ ២០១៣ នេះ ការសាងសង់នៅមិនទាន់ចាប់ផ្តើមដំណើរការនៅឡើយទេ ។ វាមិនច្បាស់ទេថា តើរៀតណាម ដែលកម្ពុជាបានទាក់ទងសុំហិរញ្ញប្បទានសម្រាប់សាងសង់មណ្ឌល ដែលបានគ្រោងនេះ ពិតជានឹងផ្តល់ឲ្យឬយ៉ាងណាទេ ។

យោងតាមទិន្នន័យរបស់រដ្ឋាភិបាល យ៉ាងហោចណាស់មានអ្នកជាប់ឃុំឃាំងម្នាក់ក្នុង ១០ នាក់ ក្នុងមណ្ឌល គឺជាកុមារអាយុក្រោម ១៨ ឆ្នាំ ។ កុមារខ្លះអាចប្រើគ្រឿងញៀន ចំណែកកុមារដទៃទៀតគឺជាក្មេងអនាថាតាមចិញ្ចើមថ្នល់ ដែលមិនប្រើប្រាស់គ្រឿងញៀន ប៉ុន្តែត្រូវជាប់ឃុំនៅក្នុងមណ្ឌលក្រោយពេលប្រតិបត្តិការ "បោសសំអាតដងវិថី"។កុមារប្រឈមមុខនឹងការរំលោភដូចមនុស្សចាស់ដែរ ក្នុងពេលជាប់ឃុំ៖ ពួកគេជាប់ឃុំក្នុងបន្ទប់ជាមួយមនុស្សចាស់ ត្រូវបានបង្ខំអោយធ្វើការហាត់ប្រាណយ៉ាងនឿយហាត់ និងហាត់ក្បួនទ័ព ហើយពួកគេទទួលរងការរំលោភ រួមមានប្រព្រឹត្តកម្មឃោរឃៅ អមនុស្សធម៌ បន្ថោកបន្ទាប និងទារុណកម្ម ក៏មានដែរ ។

ឧទាហរណ៍ រំចង់ ជាកុមារជំទង់ គាត់បានជាប់ក្នុងមណ្ឌលគ្រប់គ្រងដោយយោធាខេត្តកោះកុង អស់រយៈពេល ១៨ ខែ ។ គេបានចាក់សោអោយគាត់នៅក្នុងបន្ទប់មួយ ដាក់ច្រវាក់ភ្ជាប់នឹងជើងគ្រែក្នុងអាទិត្យទីមួយនៃការឃុំខ្លួន ។ ក្រោយមកគេអោយគាត់ហាត់ប្រាណរាល់ព្រឹក ។ ពួកទាហានបាននិយាយប្រាប់គាត់ថា ការហាត់ឲ្យបែកញើសនឹងជួយគាត់អោយជាសះស្បើយពីគ្រឿងញៀន ។ ទាហានបានវាយដំគាត់ដោយសារគាត់ដេកលក់ ពេលគេឲ្យគាត់បោសសំរាមនៅក្នុងបន្ទាយ ។

ការចាប់បង្ខំមនុស្សអោយចូល "ព្យាបាល" នៅក្នុងមណ្ឌលឃុំឃាំងគ្រឿងញៀន គឺរំលោភសិទ្ធិមនុស្សច្រើនប្រការរបស់ពួកគេ រួមមានការការពារពីការចាប់ខ្លួន និងការឃុំឃាំងដោយគ្មានឈរលើច្បាប់និងប្រព្រឹត្តកម្មឃោរឃៅ អមនុស្សធម៌ និងបន្ថោកបន្ទាប។ កម្មវិធីដែលមិនបែងចែកបែបនេះ រំលោភលើសិទ្ធិក្នុងច្បាប់អន្តរជាតិ ស្តីពីទទួលបានកម្រិតសុខភាពដែលមានស្តង់ដារខ្ពស់បំផុតដែលអាចទទួលបាន ។

ការព្យាបាលវេជ្ជសាស្ត្រទាំងអស់ គួរតែមានលក្ខណៈវិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រ សមស្រប និងមានគុណភាព ។ សិទ្ធិមនុស្ស ព្រមទាំងក្រមសីលធម៌ពេទ្យ ឈរលើមូលដ្ឋានគ្រឹះនៃការទទួលស្គាល់សិទ្ធិស្វ័យភាព និងស្វ័យសម្រេច និងសារៈសំខាន់នៃការឯកភាពដោយទទួលដឹងព័ត៌មានជាមុន ។ ការព្យាបាលដោយបង្ខំចំពោះអ្នកអាស្រ័យលើគ្រឿងញៀន គួរអនុវត្តតែក្នុងស្ថានភាពមានវិបត្តិវិសាមញ្ញប៉ុណ្ណោះ និងដែលមានការការពារជាក់លាក់ ដើម្បីធានាថាមានបំណងឲ្យបុគ្គលនោះត្រឡប់ទៅរកស្ថានភាពមួយដែលមានស្វ័យភាព លើការសម្រេចទទួលយកការព្យាបាលដោយខ្លួនឯង ។ ការព្យាបាលនោះក៏គួរតែមានរយៈពេលខ្លី និងមានការកំណត់ពេលយ៉ាងច្បាស់លាស់ និងគួរទទួលបានការពិនិត្យឡើងវិញជាប្រចាំ ដោយអាជ្ញាធរឯករាជ្យមួយ ។ ក្នុងករណីគ្មានការបំពេញលក្ខខណ្ឌនេះ ក៏គ្មានយុត្តិកម្មធ្វើការព្យាបាលដោយបង្ខំឡើយ ។

ការចាក់សោឃុំឃាំងជនគ្មានផ្ទះសម្បែង អ្នករកស៊ីផ្លូវភេទ ក្មេងអនាថាតាមចិញ្ចើមថ្នល់ ឬមនុស្សដែលមានឬត្រូវគេឃើញថាមានសមត្ថភាពខុសគេ នៅក្នុងមណ្ឌលឃុំឃាំងគ្រឿងញៀន គ្មានមូលដ្ឋានអ្វីទាំងអស់តាមច្បាប់អន្តរជាតិ ។

ការរំលោភលើច្បាប់អន្តរជាតិជាមូលដ្ឋានទាំងនេះ មានន័យថាបុគ្គលទាំងអស់ដែលកំពុងជាប់ឃុំឃាំងក្នុងមណ្ឌលឃុំឃាំងគ្រឿងញៀននៅកម្ពុជា គួរត្រូវបានដោះលែងភ្លាម និងដោយគ្មានលក្ខខណ្ឌ ។ ដើម្បីគោរព ការពារ និងបំពេញសិទ្ធិសុខភាពរបស់អ្នកអាស្រ័យលើគ្រឿងញៀន រដ្ឋាភិបាលគួរពង្រីកការទទួលបាននូវការព្យាបាលគ្រឿងញៀនដោយស្ម័គ្រចិត្ត និងមានមូលដ្ឋានក្នុងសហគមន៍ តាមរយៈក្រសួងសុខាភិបាល ដោយមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាលមានសមត្ថភាព ។ ការពង្រីកសេវាព្យាបាលដោយស្ម័គ្រចិត្តនេះ មិនមែនជាបុរេលក្ខខណ្ឌតម្រូវឲ្យសម្រាប់បិទមណ្ឌលនោះទេ ។

ច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ ក៏តម្រូវឲ្យអោយអាជ្ញាធរស៊ើបអង្កេតរបាយការណ៍ដែលអាចជឿទុកចិត្តបាន ស្តីពីទារុណកម្ម និងប្រព្រឹត្តកម្មយង់ឃ្នងដទៃទៀត និងដាក់ទោសខាងវិន័យ ឬនាំខ្លួនអ្នកទទួលខុសត្រូវទៅកាត់ទោស ដោយសមស្រប ។ អាជ្ញាធរកម្ពុជាមិនបានចាត់វិធានការបែបនេះទេ ក្រោយពេលផ្សព្វផ្សាយរបាយការណ៍ *"ស្បែកដាច់ជាប់ខ្សែភ្លើង"* ។ ជាថ្មីម្តងទៀត អង្គការឃ្លាំមើលសិទ្ធិមនុស្ស

សូមអំពាវនាវដល់អាជ្ញាធរកម្ពុជាអោយធ្វើការស៊ើបអង្កេតជាបន្ទាន់ផ្អែកលើបាយការណ៍ស្តីពីទារុណកម្ម និងប្រព្រឹត្តកម្មយង់ឃ្នងទាំងនេះ និងសូមអោយកាត់ទោសអ្នកប្រព្រឹត្តបទល្មើស ។

ឈ្មោះ ប្រាំ អតីតអ្នកជាប់ឃុំម្នាក់ បាននិយាយថាពួកគេបានយល់អំពីមូលហេតុអ្វីបានជាការព្យាបាលគ្រឿងញៀនរបស់កម្ពុជា មានស្ថានភាពដ៏សែនអាក្រក់ ដែលគេមើលឃើញយ៉ាងច្បាស់ និងគ្មានអ្នកណាទទួលខុសត្រូវអ្វីទាំងអស់ អាចនឹងបន្តបាន ។ ដោយធ្លាប់ជាប់ឃុំឃាំងអស់រយៈពេលបីខែកន្លះនៅមណ្ឌលឱកាសខ្ញុំ កាលពីដើមឆ្នាំ ២០១៣ គាត់បានឆ្លើយបែបងាយៗថា ៖ "ពីព្រោះយើងគ្មានសិទ្ធិអ្វីទាំងអស់" ៕

# អនុសាសន៍

## ចំពោះរាជរដ្ឋាភិបាលកម្ពុជា[1]

- ដោះលែងមនុស្សទាំងអស់ដែលជាប់នៅក្នុងមណ្ឌលឃុំឃាំងគ្រឿងញៀន ដោយការបន្តឃុំឃាំងពួកគេមិនអាចធ្វើយុត្តិកម្មបានដោយផ្អែកលើមូលដ្ឋានច្បាប់ ឬសុខភាពទេ ។
- បិទមណ្ឌលឃុំឃាំងគ្រឿងញៀននៅកម្ពុជាជាស្ថាពរ ដោយសារមណ្ឌលទាំងនោះ ដាក់មនុស្សដោយរំលោភច្បាប់អន្តរជាតិ ។
- ផ្អាកភ្លាមរាល់ការរៀបចំសាងសង់មណ្ឌល"ជាតិ"ព្យាបាលការញៀនគ្រឿងញៀន ។
- ធានាឲ្យមានការស៊ើបអង្កេតមួយជាបន្ទាន់ ហ្មត់ចត់ និងមិនលំអៀង ព្រមទាំងកាត់ទោសសមស្របអ្នកដែលទទួលខុសត្រូវចំពោះបទរំលោភធ្ងន់ធ្ងរ ទាក់ទងនឹងមណ្ឌលឃុំឃាំងគ្រឿងញៀន រួមមានការចាប់ខ្លួនដោយមិនឈរលើច្បាប់ ការធ្វើទារុណកម្ម ប្រព្រឹត្តកម្ម ឬការដាក់ទណ្ឌកម្មដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប និងការឲ្យធ្វើពលកម្មដោយបង្ខំ ។
- បញ្ឈប់ការចាប់ខ្លួន ឬការឃុំខ្លួនដោយមិនឈរលើច្បាប់ អ្នកប្រើគ្រឿងញៀន និងអ្នកផ្សេងទៀតដែលគេចាត់ទុកថាជាមនុស្ស "មិនចង់បាន" ដូចជាជនគ្មានផ្ទះសម្បែង អ្នកសុំទាន ក្មេងអនាថាតាមចិញ្ចើមថ្នល់ អ្នករកស៊ីផ្លូវភេទ និងមនុស្សដែលមានឬត្រូវគេមើលឃើញថាមានសមត្ថភាពខុសគេ ។

## ចំពោះក្រសួងសុខាភិបាល

- ពង្រីកសេវាព្យាបាលការអាស្រ័យលើគ្រឿងញៀនដោយស្ម័គ្រចិត្ត និងមានមូលដ្ឋានក្នុងសហគមន៍និងធានាថាការព្យាបាលបែបនេះសមស្របតាមវេជ្ជសាស្ត្រ និងត្រូវតាមបទដ្ឋានអន្តរជាតិ។

## ចំពោះរដ្ឋាភិបាលវៀតណាម

[1] ជាពិសេសអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីយុទ្ធជន យុវនីតិសម្បទា និងសាលារាជធានីភ្នំពេញ ។

- កុំផ្តល់មូលនិធិ ការជួយរៀបចំកម្មវិធី ឬសកម្មភាព ដែលសំដៅផ្តល់ជំនួយដល់ផែនការមណ្ឌលឃុំឃាំងគ្រឿងញៀនថ្នាក់ "ជាតិ" នៅកម្ពុជា (ឬមណ្ឌលឃុំឃាំងគ្រឿងញៀនឯទៀត) ដែលទ្រទ្រង់ដល់គោលនយោបាយ ឬកម្មវិធីទាំងឡាយដែលរំលោភច្បាប់អន្តរជាតិ រួមមានការហាមប្រាមពលកម្មដោយបង្ខំ ។

**ចំពោះការិយាល័យប្រចាំប្រទេសនៃភ្នាក់ងារអង្គការសហប្រជាជាតិ និងម្ចាស់ជំនួយទ្វេភាគី និងពហុភាគីរបស់កម្ពុជា**

- អំពាវនាវជាសាធារណៈ ឲ្យដោះលែងភ្លាមមនុស្សទាំងអស់ដែលកំពុងជាប់ក្នុងមណ្ឌលឃុំឃាំងគ្រឿងញៀននៅកម្ពុជា ។
- អំពាវនាវជាសាធារណៈ អោយបញ្ចប់ការរំលោភសិទ្ធិមនុស្សដែលកើតឡើងក្នុងមណ្ឌលឃុំឃាំងគ្រឿងញៀននៅកម្ពុជា ធ្វើការស៊ើបអង្កេតគួរឲ្យជឿទុកចិត្តបាននិងមិនលំអៀង លើការចោទប្រកាន់ថាមានរំលោភបនៅមណ្ឌលទាំងនេះ និងឲ្យអ្នកទទួលខុសត្រូវចំពោះការរំលោភទទួលគណនេយ្យភាពផងដែរ ។

**ចំពោះស្ថានទូតបរទេស និងភ្នាក់ងារអង្គការសហប្រជាជាតិ ប្រចាំភ្នំពេញ**

- មុនពេលកិច្ចប្រជុំអន្តរជាតិ ឬទស្សនកិច្ចរបស់អ្នកមុខអ្នកការបរទេស ធ្វើការអំពាវនាវជាសាធារណៈ ដល់រដ្ឋាភិបាលកម្ពុជា កុំធ្វើកិច្ចប្រតិបត្តិការ "បោសសំអាតតាមដងវិថី" ប្រមូលអ្នកប្រើគ្រឿងញៀន ជនគ្មានផ្ទះសម្បែង អ្នកសុំទាន អ្នករកស៊ីផ្លូវភេទ ក្មេងអានាថាតាមចិញ្ចើមថ្នល់ និងមនុស្សដែលមានឬត្រូវគេមើលឃើញថាមានសមត្ថភាពខុសគេ ។
- បង្កើតក្រុមការងារ ដែលមានសមាសភាព បុគ្គលិកជាន់ខ្ពស់ស្ថានទូតបរទេស និងភ្នាក់ងារអង្គការសហប្រជាជាតិ មានភារកិច្ចសម្របសម្រួលការតស៊ូមតិរួម ដើម្បីបង្អាក់កិច្ចប្រតិបត្តិការរបស់អាជ្ញាធរកម្ពុជាកុំអោយ "បោសសំអាតតាមដងវិថី" នៅមុនពេលមានកិច្ចប្រជុំអន្តរជាតិ ឬទស្សនរបស់អ្នកមុខអ្នកការបរទេស និងដាក់សម្ពាធអោយដោះលែងភ្លាមបុគ្គលទាំងឡាយដែលត្រូវបានឃុំឃាំងដោយគ្មានឈរលើផ្លូវច្បាប់ដែលជាលទ្ធផលនៃកិច្ចប្រតិបត្តិការបែបនេះ ៕